# កិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យលទ្ធផល នៃការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល០១ ឆ្នាំដំបូង នៃការបង្កើតរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា




នៅព្រឹកថ្ងៃទី០៩ ខែ តុលា ឆ្នាំ២០១៤ នៅសាលប្រជុំរដ្ឋាករទឹកក្រុងភ្នំពេញ មានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យលទ្ធផល នៃការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល០១ ឆ្នាំដំបូង នៃការបង្កើតរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួម ចាប់ពីមន្ត្រីថ្នាក់ការិយាល័យឡើងទៅ និងប្រធានមន្ទីរខេត្ត–ក្រុង ផងដែរ ។



ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អ៊ុំ សុថា** អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ និងជានាយកខុទ្ទកាល័យ នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានអញ្ជើញមានប្រសាសន៍ស្វាគមន៍ដោយបានបញ្ជាក់ថា៖ ក្រោយពីរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ត្រូវបានបង្កើតឡើង កាលពីថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ រហូតមកដល់ខែធ្នូ ឆ្នាំ២០១៣ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏ត្រូវបានបង្កើតឡើងផងដែរ តាមព្រះរាជក្រមលេខ : នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ។ ទន្ទឹមនិងនោះ ថ្នាក់ដឹកនាំក្រសួង ត្រូវបានប្រកាសឱ្យចូលកាន់តំណែងជាផ្លូវការ នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៣ ។ ហេតុដូចនេះ សកម្មភាពការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទើបចាប់ផ្តើមអនុវត្តពេញលេញ ចាប់ពីខែមករា ឆ្នាំ២០១៤ រៀងរហូតមក ដែលគិតមកដល់ដំណាច់ខែ កញ្ញា នេះ ទើបមានរយៈពេល០៩ ខែប៉ុណ្ណោះ ។ ឯកឧត្តម អគ្គនាយក បានបន្តថា៖កិច្ចប្រជុំនាថ្ងៃនេះ មិនមានកម្មវិធីតាមលំដាប់លំដោយទេ ពីព្រោះរបាយការណ៍នៃលទ្ធផល បានចែកជូន ជា Soft និង Hard Copy គ្រប់គ្នាអស់ហើយ ។ ដូច្នេះ កិច្ចប្រជុំនាថ្ងៃនេះ ចាត់ទុកដូចជាវេទិកាសាធារណៈ បើកទូលាយឱ្យសមាជិកអង្គប្រជុំសម្តែងមតិរយៈពេល០៥នាទី ទៅលើរបាយការណ៍លទ្ធផល និងការងារចាំបាច់ក្នុងអង្គភាពរបស់ខ្លួន ដើម្បីថ្នាក់ដឹកនាំធ្វើការពិនិត្យ ដោះស្រាយតាមលទ្ធភាពជាក់ស្តែង ។

គួរបញ្ជាក់ថា៖ក្នុងសេចក្តីផ្តើមនៃរបាយការណ៍បានបញ្ជាក់ថា៖ ចាប់ពីបង្កើតឡើងរហូតដល់បច្ចុប្បន្ន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការរៀបចំ រចនាសម្ព័ន្ធមុខងារ និងភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទនានាទាំងអស់ ព្រមទាំងតាក់តែងរៀបចំរាល់ឯកសារគតិយុត្ត ឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យនីមួយៗ ដើម្បីពង្រឹងប្រសិទ្ធិភាព និងគុណភាពការងារ ។

ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងសិប្បកម្ម បានប្រមូលផ្តុំលើការរៀបចំគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ការធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម ការបន្តអនុវត្តកិច្ចសម្រួលនានាដល់ធុរៈជន និងសិប្បករ អាជីវករ ម្ចាស់សហគ្រាសនានា ក្នុងការទទួលបានសេវារដ្ឋបាលពីរដ្ឋ ដោយងាយស្រួល មានភាពកក់ក្តៅ និងការជឿជាក់ ដោយផ្តោតទៅលើការអនុវត្តយន្តការ ច្រកចេញ ចូលតែមួយ ក្នុងការចុះបញ្ជីបង្កើត រោងចក្រ សហគ្រាស សិប្បកម្ម រឺការផ្តល់ការអនុញ្ញាតនានា ។ ការជួយអភិវឌ្ឍន៍ផ្នែកឯកជន ក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងសកម្ម តាមរយៈការជម្រុញ ការលើកកំពស់គុណភាពផលិតផល ការពង្រីកសមត្ថភាពផលិត សមត្ថភាពប្រកួតប្រជែង ការជម្រុញដល់ការពង្រីកមុខរបរខ្នាតតូច និងមធ្យម និងការអភិវឌ្ឍន៍ទីផ្សារសម្រាប់ផលិតផលកម្ពុជា ទាំងទីផ្សារក្នុងស្រុក និងទីផ្សារបរទេស ។ល។

ជារួមវិស័យឧស្សាហកម្ម និងសិប្បកម្ម បន្តចូលរួមក្នុងការរក្សានិរន្តរភាព និងកំណើនសេដ្ឋកិច្ចជាតិ ដោយបានធ្វើឱ្យសម្រេចនូវសមិទ្ធិផលជាច្រើន សំដៅលើកកំពស់ការជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរ ឡើងពីមួយថ្ងៃ ទៅមួយថ្ងៃ និងឈានទៅកាត់បន្ថយភាពក្រីក្ររបស់ប្រចាពលរដ្ឋ ។ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់បានខិតខំបំពេញភារកិច្ចរបស់ខ្លួន យ៉ាងសកម្ម សំដៅអភិវឌ្ឍន៍កម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបានភាពជោគជ័យជាបន្តបន្ទាប់ ។

ការបូកសរុបសកម្មភាពការងារតាមវិស័យជំនាញ និងការឆ្លុះបញ្ចាំងឡើងវិញនូវលទ្ធផលនៃការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការងារស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងរយៈពេល ០៩ខែ ដើមឆ្នាំ២០១៤ ដែលក្នុងរបាយការណ៍ត្រូវបានចែកចេញ ជា០៣ ផ្នែក គឺ ទី១:អំពីលទ្ធផលការងារតាមវិស័យជំនាញ ទី២:លទ្ធផលនៃការចូលរួមអនុវត្តកំណែទម្រង់ការងារស៊ីជម្រៅលើគ្រប់វិស័យ និងទី៣: ទិសដៅការងារសម្រាប់ត្រីមាសទី៤ និងឆ្នាំខាងមុខ ។



បន្ទាប់ពីអង្គពិធី បានផ្តល់ឱកាសឱ្យថ្នាក់ដឹកនាំ និងសមាជិកអង្គប្រជុំ ដែលមានបំណងឡើងមានមតិ យោបល់ និងសំណូមពរ ក៏ដូចជាការបង្ហាញនូវការគាំទ្រចំពោះរបាយការណ៍រួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអញ្ជើញមានប្រសាសន៍បកស្រាយ និងដោះស្រាយបញ្ហាជាក់ស្តែងជាច្រើន ដែលសមាជិកអង្គប្រជុំបានលើកឡើង រួមមាន ដូចជា: ការមិនសហការរវាងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ពីម្ចាស់ រោងចក្រ សិប្បកម្មផលិតទឹកបរិសុទ្ធ និងអង្គភាពផលិតទឹកស្អាតឯកជន មួយចំនួន ឯកឧត្តម ទេសរដ្ឋមន្ត្រី បានជម្រាបថា:ការត្រួតពិនិត្យគឺជាកាតព្វកិច្ចតាមផ្លូវច្បាប់ ម្ចាស់រោងចក្រ សិប្បកម្ម មិនអាចមិនសហការបានឡើយ ។ តែធ្វើយ៉ាងណាឱ្យស្របតាមគោលការណ៍ច្បាប់ ដោយមិនត្រូវទៅរំខានគេឡើយ ។ ទាក់ទង និងការលើកឡើងពីតំណាងស្ត្រី ក្នុងវិទ្យាស្ថានស្តង់ដារ ថាមានការរើសអើង ក្នុងការតម្លើងឋានៈតួនាទីស្ត្រី ក្នុងអង្គភាពក៏ដូចជាការបញ្ជូនស្ត្រី ទៅសិក្សាក្រៅប្រទេសជាដើម ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:នេះជាការតែងតាំងតាមរយៈការវិនិច្ឆ័យពីប្រធានអង្គភាព និងអ្នកគ្រប់គ្រងផ្ទាល់ ។ ប៉ុន្តែ ជាជំហរផ្ទាល់របស់ឯកឧត្តម គឺលើកស្ទួយជានិច្ចនូវឋានៈតួនាទីរបស់ស្ត្រី ។ ជាក់ស្តែងមកដល់ថ្ងៃនេះ បងប្អូនស្ត្រី ត្រូវបានក្រសួងធ្វើការតែងតាំងជាច្រើន ចាប់ពីថ្នាក់អនុការិយាល័យ រហូតដល់អគ្គនាយិកា ។ ក្នុងនោះ ឋានៈជាប្រធាននាយកដ្ឋានមានរហូតដល់០៤ រូប ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យស្ត្រីក្នុងក្រសួង ខិតខំពង្រឹងសមត្ថភាព និងចំណេះ ជំនាញរបស់ខ្លួន បន្ថែម ដើម្បីទទួលបានការតែងតាំងជាបន្តបន្ទាប់ទៀត ។ ក្រៅពីនោះ ជាការបន្ថែមចំពោះការលើកឡើងពីសមាជិកអង្គប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានធ្វើការណែនាំមួយចំនួនដូចតទៅ :-ខិតខំបន្តការចុះធ្វើអធិការកិច្ចតាមបណ្តា រោងចក្រ សិប្បកម្ម ក្នុងសកម្មភាពដូចភ្លៀងរលឹម និងចងចាំថា:ការចុះទៅនោះ គឺដើម្បីអប់រំ ណែនាំ ឱ្យម្ចាស់រោងចក្រ សិប្បកម្ម គោរពច្បាប់

ទម្លាប់ និងស្តុំដារផលិតកម្ម ដោយមិនត្រូវទៅរំខានគេឡើយ ។ ការចុះនោះ ត្រូវមានក្រុមចម្រុះ និងប្រា ប់ម្ចាស់រោងចក្រ សិប្បកម្ម ឱ្យបានដឹងជាមុន ។ ឯកឧត្តម បានស្នើឱ្យមន្ត្រីជំនាញពន្លឿនការតាក់តែងសៀវភៅអធិការកិច្ច ដែលយើងចាត់ទុកថា: ជាសៀវភៅមគ្គុទេសន៍សម្រាប់ក្រុមចម្រុះអធិការកិច្ច និងម្ចាស់រោងចក្រ សិប្បកម្ម ហើយក៏នឹងដាក់បញ្ចូល ក្នុងគេហទំព័ររបស់ក្រសួងផងដែរ ពីព្រោះសៀវភៅនេះ បានណែនាំពីនិតិវិធី ភារកិច្ច នៃការធ្វើអធិការកិច្ច និងលក្ខខ័ណ្ឌតម្រូវនានាសម្រាប់ម្ចាស់រោងចក្រ សិប្បកម្ម ធ្វើការស្វ័យស្វែងយល់ –ពង្រឹងការចុះពិនិត្យ និងធ្វើព្យាសកម្មចំពោះប្រភេទជញ្ជីញថ្លឹងក្រោម១០០ គ.ក្រ ទោះបីតាមច្បាប់កិច្ចការនេះ មិនតម្រូវឱ្យបង់កម្រៃសេវាក៏ដោយ–ការងារបំពាក់បំប៉នសមត្ថភាពមន្ត្រី គឺត្រូវតែពង្រឹង ទាំងថ្នាក់កណ្តាល និងមន្ទីខេត្ត ក្រុង ដូចជា:ជំនាញការចុះធ្វើអធិការកិច្ច និងការងារបញ្ញត្តិកម្មជាដើម–ធ្វើការរៀបចំឡើងវិញពីសមាគមមន្ត្រីរាជការក្រសួង ហើយបើមានមន្ត្រីរបស់ក្រសួងមានទុក្ខធុរៈត្រូវមានថវិកាឧបត្ថម្ភ និងមន្ត្រីចុះសួរសុខទុក្ខ ។ ឯកឧត្តមផ្ទាល់ នឹងឧបត្ថម្ភទឹកប្រាក់ចំនួន១០០ដុល្លារ សម្រាប់គ្រួសារមន្ត្រី ដែលទទួលមរណៈភាព ។ ការស្នើសុំសំភារៈការិយាល័យ កំព្យូទ័រ ម៉ាស៊ីន Printer និងកង្វះខាតមន្ត្រីក្នុងអង្គភាពនីមួយ ក្រសួងនិងខិតខំដោះស្រាយជាបណ្តើៗ ហើយឯកឧត្តម ក៏បានស្នើឱ្យពន្លឿនការបែងចែកទ្រព្យសម្បត្តិ ជាអចលនទ្រព្យ រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ ថាមពលផងដែរ។ ដោយឡែក ចំពោះនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដែលត្រូវការជួលអ្នកជំនាញការនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានផ្តល់សារៈសំខាន់លើការងារនេះ–ចំពោះការយឺតយ៉ាវការសាងសង់អគារធ្វើការងាររបស់វិទ្យាស្ថានស្តង់ដាកម្ពុជា។ ការងារនេះមិនត្រូវឱ្យពន្យាពេលទៀតទេ ត្រូវតែឱ្យក្រុមហ៊ុនសាងសង់អនុវត្តតាមកិច្ចសន្យា–ទាក់ទងនិងការលើកឡើងថា មានភាពស្មុគស្មាញ ចំពោះការចេញអាជ្ញាប័ណ្ណធ្វើអាជីវកម្មទឹកស្អាត ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: ការងារទឹកស្អាត ត្រូវតែមានការប្រុងប្រយ័ត្នបំផុត ពីព្រោះទាក់ទងនិងសុខភាពសាធារណៈ ។ ទោះជាយ៉ាងណា ការងារនេះនឹងមានកោះប្រជុំ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែ វិច្ឆិកា ខាងមុខ ដែលនឹងមានការណែនាំពីនីតិវិធី គោលដៅ រួមទាំងអនុញ្ញាតឱ្យអាជីវករទឹកស្អាតលើកឡើងពីសំណូមពរ និងតម្រូវការរបស់ពួកគេផងដែរ ។



ស្ថិតក្នុងឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹង ប្រែងជារួម នៃថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទាំងអស់ អនុវត្តបានលទ្ធផលគួរគាប់ប្រសើរនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល១ ឆ្នាំ នៃរាជរដ្ឋាភិបាលអណត្តិទី៥ នេះ ។ ជាការតបស្នងសងគុណ ក្រសួងបានស្នើទៅគណៈរដ្ឋមន្ត្រី ដើម្បីបំពាក់មេដាយការងារជូនមន្ត្រីក្រោមឱវាទចំនួន៧០៨នាក់ ដែលនេះជាការបំពាក់លើកទី២ ដល់មន្ត្រីដែលមិនទាន់ទទួលបាននៅលើកទី១។ ក្នុងនោះក្រសួង បានធ្វើប្រកាសតែងតាំងមន្ត្រីចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ការិយល័យចំនួន ១៦៧ នាក់ បន្ថែមទៀត ។ ម៉្យាងនៅថ្ងៃទី១១ ខាងមុខ ក្រសួងនឹងរៀបចំប្រលងប្តូរក្របខ័ណ្ឌ ដល់មន្ត្រីក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។ រីឯការធ្វើនិយ័តកម្មកាំប្រាក់មន្ត្រីរាជការ និងការប្រលងជ្រើសរើសមន្ត្រីបំពេញក្របខ័ណ្ឌថ្មីក៏ក្រសួងបានធ្វើរួចរាល់ហើយផងដែរ ។

ជាចុងក្រោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានណែនាំឱ្យថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទទាំងអស់បន្តខិតខំបំពេញការងារ និងរក្សាសាមគ្គីភាពផ្ទៃក្នុងឱ្យកាន់តែល្អប្រសើរ ជាពិសេសត្រូវរួមគ្នាអនុវត្តឱ្យបានជោគជ័យ នៅពេលច្បាប់ស្តីពីកាគ្រប់គ្រងរោងចក្រ និងសិប្បកម្មត្រូវបានចូលជាធរមាន ដែលសេចក្តីព្រាងច្បាប់នេះ បច្ចុប្បន្នត្រូវបានអនុម័តពីអង្គសភា និងព្រឹទ្ធសភារួចរាល់ហើយ ហើយឯកឧត្តមបានទៅការពារច្បាប់នេះដោយផ្ទាល់នាពេលថ្មីៗនេះ ។

